# របាយការណ៍
# របស់ឯកឧត្តម ម៉ក់ រ៉ា ប្រធានក្រុមប្រឹក្សាខេត្តពោធិ៍សាត់
# ក្នុងសន្និសីទសារព័ត៌មាន ស្តីពីវឌ្ឍនភាពការងារប្រចាំឆ្នាំ២០២០
# និងលើកទិសដៅការងារឆ្នាំ២០២១ របស់រដ្ឋបាលខេត្តពោធិ៍សាត់
# ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២១

**ជាបឋមខ្ញុំព្រះករុណា ខ្ញុំបាទ**!

- សូមក្រាបថ្វាយបង្គំសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះសង្ឃរាជ សម្តេចព្រះរាជាគណៈ និងព្រះថេរានុថេរៈគ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ!
- សូមគោរព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!
- សូមគោរព **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាទីគោរពដ៏ខ្ពង់ខ្ពស់!
- ឯកឧត្តម **ផៃ ស៊ីផាន** រដ្ឋមន្ត្រី ប្រតិភូអមនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់!
- ឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនអ្នកសារព័ត៌មានទាំងអស់ដែលមានវត្តមាននាឱកាសនេះ ជាទីគោរពរាប់អាន!

ក្នុងនាមរដ្ឋបាលខេត្តពោធិ៍សាត់ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវសេចក្តីសោមនស្សរីករាយ និងមានកិត្តិយស ដែលត្រូវបានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលអញ្ជើញឲ្យចូលរួមជាវាគ្មិនកិត្តិយស ដើម្បីធ្វើបទបង្ហាញ ស្តីពីវឌ្ឍនភាពការងារប្រចាំឆ្នាំ២០២០ និងលើកទិសដៅការងារឆ្នាំ២០២១ របស់រដ្ឋបាលខេត្តពោធិ៍សាត់ នាឱកាសនេះ។

**សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីមេត្រី!**

ឆ្លៀតក្នុងឱកាសដ៏មានសារៈសំខាន់នេះ ខ្ញុំសូមអនុញ្ញាតរាយការណ៍សង្ខេប អំពីស្ថានភាពទូទៅនៃខេត្តពោធិ៍សាត់ សក្តានុពល សមិទ្ធផលសំខាន់ៗនៃការអភិវឌ្ឍ ស្ថានភាពសេដ្ឋកិច្ច ការគ្រប់គ្រងដឹកនាំ និងវឌ្ឍនភាពការងាររបស់ក្រុមប្រឹក្សា និងគណៈអភិបាលខេត្ត នៅមូលដ្ឋានឃុំ សង្កាត់ សម្រេចបានរយៈពេល២ឆ្នាំកន្លងមក នៃអាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្តពោធិ៍សាត់ មានដូចខាងក្រោម៖

## I. ស្ថានភាពទូទៅ

ខេត្តពោធិ៍សាត់ ស្ថិតនៅភាគពាយ័ព្យនៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយ ១៨៦គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ។ មានព្រំប្រទល់ខាងកើតជាប់នឹងខេត្តកំពង់ឆ្នាំង ខាងលិចជាប់នឹងខេត្តបាត់ដំបង និងប្រទេសថៃ (ខ្សែបន្ទាត់ព្រំដែន ប្រវែងប្រមាណ ៨០ គ.ម) ខាងជើងទល់នឹងបឹងទន្លេសាប (ប្រវែងប្រមាណ ៨៦គ.ម) និងខាងត្បូងជាប់នឹងខេត្តកំពង់ស្ពឺ និងខេត្តកោះកុង។ មានផ្ទៃដីសរុបចំនួន ១២.៦៩២ គ.ម$^២$ ស្មើនឹង១.២៦៩.២០០ ហ.ត និងចែកចេញជា ០១ រដ្ឋបាលក្រុង ០៦ រដ្ឋបាលស្រុក ០៧ សង្កាត់ ៤២ឃុំ និង៥១១ភូមិ។

មានប្រជាជនសរុបចំនួន **៥០០,៦៩៩ នាក់** ស្រី **២៤៧,៥៨៧ នាក់** ស្មើនឹង **១១៩,៧០៩ គ្រួសារ** មេគ្រួសារជាស្ត្រីចំនួន **១៧.៦៧%**។ មានមុខរបរជាកសិករ ៧៥.៨% សេវាករ ២៣.៥% និងសិប្បករ ០.៧%។

**ផ្ទៃដីត្រូវបានបែងចែក ជា ៤ ប្រភេទ ដូចខាងក្រោម៖**

-តំបន់ទំនាបកណ្តាល៖ មានផ្ទៃដីចំនួន ១២៨,៩៥១ ហិចតា ស្មើនឹង ១០,១៦%

-តំបន់ខ្ពង់រាបៈ មានផ្ទៃដីចំនួន ១៥៩,១៥៨ ហិចតា ស្មើនឹង ១២,៥៤%
-តំបន់ភ្នំៈ មានផ្ទៃដីចំនួន ៨៥៦,៤៥៦ ហិចតា ស្មើនឹង ៦៧,៤៨%
-តំបន់បឹងទន្លេសាបៈ មានផ្ទៃដីចំនួន ១២៤,៦៣៥ ហិចតា ស្មើនឹង ៩,៨២%

ក្រុមប្រឹក្សាខេត្តពោធិ៍សាត់ អាណត្តិទី៣នេះ បានប្រសូត្រចេញពីការបោះឆ្នោតដូចបានកំណត់នៅក្នុងច្បាប់រៀបចំអង្គការ កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៩កន្លងទៅនេះ ដឹកនាំដោយ**ឯកឧត្តម ម៉ក់ រ៉ា** ប្រធានក្រុមប្រឹក្សាខេត្ត និងមានសមាជិក សមាជិកាសរុបចំនួន ២០ រូប ក្នុងនោះស្ត្រីចំនួន ២ រូប ដែលភាគច្រើនជាអតីតថ្នាក់ដឹកនាំប្រធានមន្ទីរ អង្គភាពនៃ ស្ថាប័នរដ្ឋ មានកម្រិតវប្បធម៌ចាប់ពីមធ្យមសិក្សាទុតិយភូមិរហូតដល់អនុបណ្ឌិត។ សមាសភាពក្រុមប្រឹក្សាក្រុង ស្រុកចំនួន **១២១រូប** (ស្រី**១៩រូប**) និងក្រុមប្រឹក្សាឃុំ សង្កាត់ មានចំនួន **៣១៨រូប** (ស្រី**៥៤រូប**)។ក្រុ។ ដោយឡែកគណៈអភិបាលខេត្ត ដឹកនាំដោយ**ឯកឧត្តម ម៉ៅ ធនិន** អភិបាលនៃគណៈអភិបាលខេត្ត មានអភិបាលរងខេត្តចំនួន០៦ រូប ជាស្ត្រី ០១ រូប ដែលសុទ្ធសឹងតែបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រ បរិញ្ញាប័ត្រជាន់ខ្ពស់ និងបណ្ឌិត ប្រកបដោយបទពិសោធន៍ និងទទួលបានការសិក្សាវគ្គខ្លី វែងនៅក្រៅប្រទេសជាច្រើន។ ផ្អែកតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ថ្នាក់ដឹកនាំខេត្ត មានចក្ខុវិស័យច្បាស់លាស់ក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ ដែលធ្វើឲ្យប្រជាពលរដ្ឋរស់នៅបានសុខសាន្ត មានជីវភាពធូធារតាមរយៈកិច្ចការសំខាន់ៗ ដូចជាៈ ការអភិវឌ្ឍធនធានមនុស្ស ពង្រឹងការដឹកនាំអនុវត្តតួនាទីភារកិច្ចស្របតាមជំនាញ បទពិសោធន៍ ការផ្លាស់ប្តូរទស្សនៈ ឥរិយាបទរបស់ថ្នាក់ដឹកនាំ និងមន្ត្រីក្រោមឱវាទ ដែលឈានទៅរកការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព សមធម៌ និងចីរភាព។

## II. មុខងាររបស់ក្រុមប្រឹក្សា កិច្ចសហការ និងវឌ្ឍនភាពការងារ

### ១.តួនាទី និងមុខងាររបស់ក្រុមប្រឹក្សាខេត្ត

ក្រុមប្រឹក្សាខេត្តដែលបានបង្កើតឡើងដោយការបោះឆ្នោត ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ គឺជាតំណាងសាធារណៈ ជាអ្នកការពារ និងជាអ្នកបម្រើឱ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រុមប្រឹក្សាខេត្ត ត្រូវប្រតិបត្តិតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាដែលនៅជាធរមាន។

អនុវត្តតាមតួនាទី និងភារកិច្ចដែលបានកំណត់ក្នុងបទប្បញ្ញត្តិ ក្រុមប្រឹក្សាខេត្ត អាណត្តិទី៣នេះ សម្រេចបានការងារសំខាន់ៗ ដូចខាងក្រោមៈ

- បានប្រជុំទៀងទាត់ស្របតាមប្រតិទិនស្តីពីកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាខេត្ត អនុវត្តតាមបទបញ្ជាផ្ទៃក្នុងដោយសង្កេតឃើញថាពីកិច្ចប្រជុំមួយទៅកិច្ចប្រជុំមួយមានការរីកចម្រើនលើការពិភាក្សាយ៉ាងផុសផុលលើវឌ្ឍនភាពការងាររបស់រដ្ឋបាលខេត្ត តាមរយៈការត្រួតពិនិត្យលើរបាយការណ៍ប្រចាំខែ និងការឆ្លើយបំភ្លឺជូនអង្គប្រជុំពីបណ្តាមន្ទីរ អង្គភាពជំនាញ និងអ្នកពាក់ព័ន្ធប្រកបដោយការទទួលខុសត្រូវ។
- បានរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្តឆ្នាំទី២ អាណត្តិទី៣ ឆ្នាំ២០២០ នៅតាមបណ្តាក្រុង ស្រុកទាំង៧ សរុបអ្នកចូលរួមមានចំនួន ១.២៥១នាក់ (ស្រី ៣៨០នាក់) ក្នុងនោះៈ មានសំណួរ និងសំណូមពរព្រមទាំងទុក្ខកង្វល់ទាំងឡាយ ដែលប្រជាពលរដ្ឋបានលើកឡើង

មានចំនួន ១៣២សំណួរ និងសំណូមពរ ដោយបានដោះស្រាយផ្ទាល់បាន ៩៥% នៅសល់ ៥% ទៀត នឹងដោះស្រាយបន្តនៅពេលក្រោយ។

- ក្រុមការងារផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ បានចុះធ្វើសកម្មភាពផ្ទាល់ជាមួយប្រជាពលរដ្ឋដូចភ្លៀងរលឹមដល់មូលដ្ឋាន ក្នុងគោលបំណងចង់ដឹងសុខទុក្ខ ក្តីកង្វល់របស់ប្រជាពលរដ្ឋ ដើម្បីមានវិធានការដោះស្រាយបានទាន់ពេលវេលា។
- តាមអនុសាសន៍ដ៏ថ្លៃថ្លារបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្ត ថ្នាក់ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ បានចុះធ្វើវេទិកាសាធារណៈ និងបន្តសកម្មភាពបាញ់ឆ្កោះទៅមូលដ្ឋាន ធ្វើឲ្យប្រជាពលរដ្ឋទូទាំងគាំទ្រយ៉ាងពេញទំហឹង និងសប្បាយរីករាយចំពោះការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេច និងគាំទ្រសម្តេច សូមបន្តការដឹកនាំប្រទេសជាតិប្រកបដោយសុខសន្តិភាព និងមានការអភិវឌ្ឍជាបន្តបន្ទាប់ទៅមុខទៀត។
- បានរៀបចំកិច្ចប្រជុំសម្ងាត់ដើម្បីវាយតម្លៃតែងតាំង ផ្លាស់ប្តូរមុខតំណែងមន្ត្រី ស្របតាមលិខិតបទដ្ឋានគតិយុត្ត និងប្រកបដោយយុត្តិធម៌
- បានរៀបចំសេចក្តីសម្រេចស្តីពីការបែងចែកភារកិច្ច ជូនដល់សមាជិកក្រុមប្រឹក្សាខេត្ត ជួបប្រាស្រ័យទាក់ទង និងសហការជាមួយក្រុមប្រឹក្សាក្រុង-ស្រុក ក្រុមប្រឹក្សាឃុំ-សង្កាត់ មន្ទីរអង្គភាពជំនាញ និងជាមួយប្រជាពលរដ្ឋក្នុងខេត្ត
- បានទទួលការបណ្តុះបណ្តាលជាបន្តបន្ទាប់តាមរយៈវគ្គបណ្តុះបណ្តាល ហ្វឹកហ្វឺនផ្ទាល់ ហើយបានធ្វើឲ្យសមាជិកក្រុមប្រឹក្សាមានការយល់ដឹងពីតួនាទីរបស់ខ្លួនបានល្អប្រសើរ
- បានចូលរួមសកម្មភាពនានាទាំងសកម្មភាពអភិវឌ្ឍន៍ សកម្មភាពសង្គម និងផ្នែកសាសនាជាមួយថ្នាក់ដឹកនាំខេត្ត និងបានចែករំលែកព័ត៌មានដល់សមាជិកនានាក្នុងជួរក្រុមប្រឹក្សា
- បានបង្កើតគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋ ថ្នាក់ខេត្ត ស្របតាមខ្លឹមសារអនុក្រឹត្យរបស់រាជរដ្ឋាភិបាល និងគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃ
- ពិនិត្យ និងអនុម័តសេចក្តីណែនាំ ស្តីពីដំណើរការរៀបចំកសាងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល(២០២១-២០២៣) ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់, សេចក្តីព្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២១-២០២៣) និងសេចក្តីព្រាង គម្រោងថវិកាខេត្ត សម្រាប់ការគ្រប់គ្រងឆ្នាំ២០២១
- ពិនិត្យ និងអនុម័តសេចក្តីព្រាងប្រតិទិននៃកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាខេត្ត រយៈពេលដប់ពីរ(១២ខែ)
- ពិនិត្យ និងអនុម័តសេចក្តីព្រាង និមិត្តសញ្ញារបស់រដ្ឋបាលខេត្តពោធិ៍សាត់ គម្រោងសាងសងស្ពានអាកាសថ្មើរជើងផ្លូវជាតិលេខ៥ ជាប់របងសារៈមន្ទីរខេត្តពោធិ៍សាត់ និងគម្រោងការដាំដើមឈើនៅតាមបណ្តោយផ្លូវវាងក្រុងថ្មី

## ២.កិច្ចសហការរបស់ក្រុមប្រឹក្សាខេត្ត

- ការគាំទ្រសកម្មភាព ផអ៣ នៅថ្នាក់ខេត្ត និងនៅថ្នាក់មូលដ្ឋានក្រុង ស្រុក និងឃុំ សង្កាត់
- ការគ្រោងថវិការប្រចាំឆ្នាំត្រូវបានពិភាក្សាក្នុងក្រុមការងារដែលមានតំណាងក្រុមប្រឹក្សាចូលរួម និងបានជជែកដេញដោល ដើម្បីសម្រេចទៅលើថវិកាគុណប្រយោជន៍ខេត្តឲ្យចំគោលដៅ និងប្រកបដោយសមធម៌រវាងក្រុង ស្រុក ឲ្យមានតុល្យភាពរវាងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងអរូបវន្ត
- គាំទ្រការរៀបចំអនុវត្តគម្រោងវិនិយោគខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ឆ្នាំ២០២០ និងការលើកសំណើគម្រោងសម្រាប់ឆ្នាំ២០២១

- កិច្ចសហប្រតិបត្តិការយ៉ាងល្អរវាងក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្ត ប្រៀបដូចប្ដីនិងប្រពន្ធ។ យើងខ្ញុំនៅចងចាំជានិច្ចអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងពេលដែលសម្ដេច បានអញ្ជើញជាគណអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបិទសន្និបាតប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃថា៖ ប្រធានក្រុមប្រឹក្សាខេត្ត និងអភិបាលខេត្ត ត្រូវអង្គុយធ្វើការជាមួយគ្នា ដើម្បីដឹកនាំគ្រប់គ្រងទទួលខុសត្រូវក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រួមគ្នាបម្រើប្រជាពលរដ្ឋ។
- កិច្ចការទំនាក់ទំនងរវាងគណៈអភិបាលខេត្ត និងក្រុមប្រឹក្សាខេត្តមានភាពរលូន មិនតែប៉ុណ្ណោះទំនាក់ទំនងរវាងមន្ទីរ/អង្គភាពជំនាញជុំវិញខេត្តជាមួយក្រុមប្រឹក្សាខេត្តក៏មានភាពល្អប្រសើរ ដោយក្រុមប្រឹក្សាបានអញ្ជើញតំណាងស្ថាប័នទាំងនេះមកចូលរួមប្រជុំទៀងទាត់ដើម្បីរាយការណ៍
- ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្តបានរៀបចំវេទិកាសាធារណៈស្ដីពីការដោះស្រាយវិវាទលើមូលដ្ឋានក្រៅប្រព័ន្ធតុលាការ និងសំណូមពរ ដែលជាតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋ ប្រកបដោយគុណភាព ប្រសិទ្ធភាព និងយុត្តិធម៌ ដោយអនុវត្តយ៉ាងម៉ឺងម៉ាត់តាមគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃ និងបទបញ្ជារដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងមួយសប្ដាហ៍បានបើកវេទិកា២ដង គឺថ្ងៃចន្ទ និងថ្ងៃព្រហស្បតិ៍ ដោយមានទីតាំង០១កន្លែង មានក្រុមការងារជាសេនាធិការប្រចាំការនៅសាលាខេត្ត០១ក្រុម ជាអ្នកទទួលពាក្យបណ្ដឹងឬសំណូមពររបស់ប្រជាពលរដ្ឋ ស្ថិតក្នុងបរិវេណសាលាខេត្ត។ អង្គវេទិកានេះមានសមាសភាពពី៖ ឯកឧត្តមអភិបាលខេត្ត អភិបាលរងខេត្ត, ឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្តនិងសមាជិក, អាជ្ញាធរមូលដ្ឋានក្រុង ស្រុក ឃុំ សង្កាត់ និងមន្ទីរ/អង្គភាពជំនាញពាក់ព័ន្ធ។ ក្នុងមួយថ្ងៃមានពី៣០ករណីទៅ ៦០ករណី ត្រូវប្រើពេលចាប់ពីម៉ោង៨ព្រឹក រហូតអស់បញ្ហា (ពេលខ្លះដល់ម៉ោង៥ល្ងាច)។ ករណីខ្លះ ដោយភាគីទាំងពីរមិនទាន់ឯកភាពគ្នាស្រុះស្រួលទទួលយកបាន ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត និងមន្ទីរជំនាញពាក់ព័ន្ធ សហការជាមួយអាជ្ញាធរមូលដ្ឋានបានបន្តចុះដល់មូលដ្ឋានជាក់ស្ដែងតាមបណ្ដាក្រុង ស្រុក ឃុំ សង្កាត់ទូទាំងខេត្ត ក្នុងនោះឃុំ សង្កាត់ខ្លះមានចម្ងាយផ្លូវ១៨៦គ.ម ដូចជាឃុំថ្មដា ជាប់ខ្សែបន្ទាត់ព្រំដែន ខេត្តត្រាត ប្រទេសថៃ និងឃុំអូរសោមក្នុងស្រុកវាលវែង ជាប់ព្រំប្រទល់ ខេត្តកំពង់ស្ពឺនិងកោះកុង។ ពេលចុះដល់មូលដ្ឋាន តំបន់មួយចំនួនដូចជាឃុំអូរសោម ស្រុកវាលវែង ពេលថ្ងៃប្រជាពលរដ្ឋភាគច្រើនជាប់រវល់ប្រកបមុខរបរធ្វើស្រែចំការពុំមានពេលមកចូលរួម។ វេទិកាបានឯកឧត្តមអភិបាលខេត្ត ក្រុមប្រឹក្សាខេត្តបានកំណត់យកពេលយប់ដើម្បីធ្វើការដោះវិវាទឬសំណូមពរផ្សេងៗរបស់ពួកគាត់វិញ។
- ក្នុងពេលវេទិកា ថ្នាក់ដឹកនាំខេត្ត បានត្រៀមបំរុងជាស្រេចនូវសំភារៈ គ្រឿងឧបភោគ បរិភោគ មានអង្ករថ្នាំពេទ្យ មី ក្រមា ម៉ះ អាល់កុល និងថវិកាមួយចំនួន។ល។ សម្រាប់ចែកជូនពួកគាត់ ដែលមានមានជីវភាពខ្វះខាតជីវភាព។
- រៀងរាល់ថ្ងៃក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្តតែងចែកអង្ករ ត្រីខមីសម្ភារៈផ្សេងៗជូនប្រជាពលរដ្ឋខ្វះខាតជីវភាពដែលអញ្ជើញមកពីតាមបណ្ដាក្រុងស្រុក។
- ទន្ទឹមនេះក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត បានត្រៀមបំរុងអង្ករ និងសម្ភារៈគ្រឿងឧបភោគបរិភោគជាច្រើនតោន សម្រាប់ចែកជូនប្រជាពលរដ្ឋជាប្រចាំ តាមរយៈការអញ្ជើញមកផ្ទាល់ និងតាមរយៈក្រុមការងារ ចុះមូលដ្ឋានគ្រប់លំដាប់ថ្នាក់។ ការដោះស្រាយវិវាទនិងសំណូមពរផ្សេងៗ របស់ប្រជាពលរដ្ឋកន្លងមក គឺផ្អែកតាមគោលការណ៍ច្បាប់ លិខិតបទដ្ឋាននានាជាធរមាន និងស្របតាម

ស្ថានភាពជាក់ស្តែង ដោយឈរលើគោលនយោបាយឈ្នះៗ និងគោលការណ៍ភូមិ ឃុំ មានសុវត្ថិភាព ប្រកបដោយ ប្រសិទ្ធភាព គុណភាព និងយុត្តិធម៌ អាចទទួលយកបានទាំងអស់គ្នា។

- ក្រៅពីនេះ ក្រោមការដឹកនាំរបស់**ឯកឧត្តម ស៊ុយ សែម** ប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តពោធិ៍សាត់ **ឯកឧត្តម ម៉ៅ ធនិន** អភិបាលខេត្ត និង**ឯកឧត្តម កែវ រតនៈ** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គនាយកអគ្គិសនីកម្ពុជា ឯកឧត្តម លោកជំទាវ សមាជិកព្រឹទ្ធសភា រដ្ឋសភាមណ្ឌលពោធិ៍សាត់ និងសហការីបានចុះតាមបណ្តាក្រុង ស្រុក ឃុំ សង្កាត់ ដើម្បីធ្វើវេទិកាសាធារណៈជួយដោះស្រាយរាល់បញ្ហាទាំងឡាយដែលកើតមានក្នុងមូលដ្ឋាន តាមបណ្តាវិស័យជាច្រើនក្នុងខេត្តដូចជា៖ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្រះទឹក ប្រឡាយ សាលារៀន មន្ទីរពេទ្យ វត្តអារាម ពិសេសគឺធ្វើយ៉ាងណាឱ្យជីវភាពរបស់ប្រជាពលរដ្ឋមានលក្ខណៈកាន់តែល្អប្រសើរឡើង ជាក់ស្តែង ឯកឧត្តម បានជួយជីកស្រះ ផ្តល់ពូជត្រី គ្រាប់បន្លែ ពូជមាន់ និងសិប្បកម្មផលិតចំណីសត្វ ថ្នាក់ដឹកនាំទាំងបីរូបនេះជាគំរូដល់ថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុកផ្សេងៗទៀតទូទាំងខេត្ត បានចុះដល់លំនៅដ្ឋានរបស់ប្រជាពលរដ្ឋ បើកឆ្នាំងបាយគាត់មើលដើម្បីបានដឹងថាជីវភាពប្រចាំថ្ងៃរបស់ពួកគាត់មានបញ្ហាអ្វីខ្លះសុខទុក ?ខគាត់យ៉ាងណា? សកម្មភាពជាប្រចាំថ្ងៃទាំងនេះ បានធ្វើឲ្យថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់នៅមូលដ្ឋាន បានដឹងសុខទុក្ខ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ដែលអនុវត្តតាមអនុសាសន៍របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ស្របតាមមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើស ដើម្បីបម្រើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។
- ចំពោះបញ្ហាការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីត១៩ ខេត្តយើងខ្ញុំបានអនុវត្តតាមវិធានការ និងបទបញ្ជារបស់**សម្តេចអគ្គមហាសេនាបតី ហ៊ុន សែន** និងសេចក្តីណែនាំរបស់ក្រសួងសុខាភិបាលជាប្រចាំ ដោយបានប្រើប្រាស់កម្លាំងសរុបទាំងក្រុមការងារថ្នាក់ជាតិ ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ និងយុវជន កងកម្លាំងប្រដាប់អាវុធមន្ត្រីរាជការទូទាំងខេត្ត ដើម្បីចុះអប់រំប្រជាពលរដ្ឋ ពិសេសប្រជាពលរដ្ឋមកពីប្រទេសថៃ ដោយមានគណៈកម្មការដឹកនាំដោយឯកឧត្តមអភិបាលខេត្ត បានរៀបចំទីតាំងចំនួន ០៣ កន្លែងចាំទទួលប្រជាពលករនៅច្រកព្រំដែនឃុំថ្មដា ស្រុកវាលវែង ដើម្បីរក្សាប្រជាពលករមកធ្វើចត្តាឡីស័ក។
- ឆ្នាំ២០២០ គ្រោះដោយទឹកជំនន់ដ៏ធំចំនួន៣លើកជួនៗគ្នា ធ្វើឱ្យខូចខាតផលដំណាំស្រូវ ស្ពាន ថ្នល់ ផ្ទះសម្បែង ភូមិដ្ឋានត្រូវរងការបំផ្លិចបំផ្លាញអស់មួយចំនួន។ តាមបទបញ្ជារបស់**សម្តេចអគ្គមហាសេនាបតី ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានគណៈកម្មការគ្រោះមហន្តរាយ ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត បានប្រើប្រាស់កម្លាំងសរុបគិតទាំងមធ្យោបាយ និងសម្ភារៈផ្សេងៗដែលមានតាមបណ្តាមន្ទីរ អង្គភាព ក្រុង ស្រុក ឃុំ សង្កាត់ទូទាំងខេត្ត ធ្វើយ៉ាងណាជន្លៀសប្រជាពលរដ្ឋទៅរកទីសុវត្ថិភាពឲ្យទាន់ពេលវេលា។ ក្រោយទឹកជំនន់ត្រូវបានបញ្ចប់ **សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន** និង**សម្តេចគតិព្រឹទ្ធបណ្ឌិត** ប្រធានកាកបាទក្រហមកម្ពុជា បានផ្តល់ស្រូវពូជចំនួន១.៨០០តោន ឃីត និងសម្ភារៈឧបភោគ បរិភោគជាច្រើន ជូនប្រជាពលរដ្ឋ ១៨០ ០០០គ្រួសារ.ដែលរងផលប៉ះពាល់ដោយទឹកជំនន់។

## ៣.វឌ្ឍនភាពការងារ និងសក្តានុពលសំខាន់ៗរបស់រដ្ឋបាលខេត្ត

សមិទ្ធផលគ្រប់វិស័យដែលសម្រេចបានក្នុងឆ្នាំ២០២០នេះ គឺបានប្រសូត្រចេញពីការខិតខំបំពេញការងាររបស់ក្រុមប្រឹក្សាខេត្តអាណត្តិទី៣ និងដោយមានកិច្ចសហការល្អពីគ្រប់ស្ថាប័ន អង្គភាព មន្ទីរជំនាញនានា និងការខិតខំប្រឹងប្រែងយកចិត្តទុកដាក់របស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់ ជាពិសេស

មានការចូលរួមរបស់ប្រជាពលរដ្ឋគ្រប់និន្នាការ ក្នុងការអភិវឌ្ឍមូលដ្ឋាន ទទួលបានលទ្ធផលគួរជាទីមោទនៈ។

**រដ្ឋបាលខេត្តពោធិ៍សាត់** ក៏បានបន្តអនុវត្តកាន់តែស៊ីជម្រៅនូវកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល លើការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ តាមរយៈការបន្តយន្តការពង្រឹងរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់គ្រប់ស្ថាប័ន និងប្រព័ន្ធគ្រប់គ្រងអភិវឌ្ឍន៍ធនធានមនុស្ស ការផ្ទេរមុខងារ និងធនធាន ព្រមទាំងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ ការពង្រឹងសមត្ថភាពមន្ត្រីសំដៅធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ បំពេញការងារដោយមានការចូលរួមប្រកបដោយគណនេយ្យភាព តម្លាភាព និងការឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋបានទាន់ពេលវេលា ធានាបាននូវការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ចូលរួមកាត់បន្ថយភាពក្រីក្រ ដើម្បីរួមចំណែកអភិវឌ្ឍន៍សង្គមជាតិប្រកបដោយចីរភាព។ ការការពារ ថែរក្សាសន្តិភាព សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត មានតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ចលនាមហាជនឲ្យចូលរួមការពារសន្តិសុខ សុវត្ថិភាពនៅក្នុងមូលដ្ឋានឱ្យបានក្លៀវក្លា ដើម្បីពង្រឹងខឿនសន្តិសុខជាតិឱ្យកាន់តែរឹងមាំ តាមរយៈការបន្តជម្រុញអនុវត្តគោលនយោបាយ (ភូមិ ឃុំ មានសុវត្ថិភាព)។

❖ **ជាក់ស្តែងក្នុងឆ្នាំ២០២០នេះ** រដ្ឋបាលខេត្តមានចំណូលសរុបចំនួន **១៧.៦៧៧ លានរៀល** ហើយបានចំណាយលើការងារអភិវឌ្ឍចំនួន **៩.៣២៩ លានរៀល** ។ ទទួលបាននូវសមិទ្ធផលសង្គម មួយចំនួនដូចជា៖

- ជួសជុលផ្លូវបេតុងលេខ ២០៨អា ស្ថិតនៅភូមិពាលញែក២ សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់
- សាងសង់អគារសាលាមត្តេយ្យ និងបឋមសិក្សា ហ៊ុន សែន អ៊ុម អៀម (០១ខ្នង ៦បន្ទប់)
- ស្ថាបនាទំនប់បង្វៀរក្បាលហុងស្ទឹងពោធិ៍សាត់
- សាងសង់អគារសាលាឃុំព្រងិល សាលាឃុំលាច និងសាលាឃុំសន្ទ្រែ។

❖ **ឯកឧត្តម បណ្ឌិត ម៉ៅ ធនិន** អភិបាលខេត្ត និង**ឯកឧត្តម កែវ រតនៈ** រដមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ដែលមានក្រុមលេខាធិការដ្ឋានមួយដឹកនាំដោយ**ឯកឧត្តម អ៊ីុច តឹមឈាង** អភិបាលរងខេត្ត និងប្រធានមន្ទីរការងារ ដែលកន្លងមកយើងគ្រប់គ្រងបានទាំងកម្មករនិងនិយោជិតគ្រប់រោងចក្រ ដែលមានកម្មករកម្មការនីកំពុងបម្រើការងារសរុបចំនួន**១៣.៦០១នាក់** កន្លងមកបានសម្របសម្រួលនិងគ្រប់គ្រងការទទួលខុសត្រូវដោះស្រាយរាល់បញ្ហាដែលកើតមានឡើងរវាងកម្មករនិយោជិក និងនិយោជកគ្រប់រោងចក្រ។

សមិទ្ធផលទាំងនេះ គឺបានរួមចំណែកកែលម្អសោភ័ណភាពទីក្រុង ឱ្យមានភាពទាក់ទាញពីប្រជាពលរដ្ឋ និងភ្ញៀវទេសចរណ៍ជាតិ អន្តរជាតិ ដើម្បីបម្រើប្រយោជន៍សាធារណៈ និងកំណើនសេដ្ឋកិច្ចសង្គម។

**ចំពោះការអនុវត្តគម្រោងមូលនិធិក្រុង ស្រុក ឆ្នាំ២០២០៖** រាជរដ្ឋាភិបាល បានវិភាជន៍មូលនិធិក្រុង/ស្រុកទាំង៧ទូទាំងខេត្តសរុបចំនួន **៨.៨៤៨ លានរៀល**។

**ចំពោះការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០២០៖** រាជរដ្ឋាភិបាល បានវិភាជន៍មូលនិធិឃុំ/សង្កាត់ទាំង៤៩ទូទាំងខេត្ត សរុបចំនួន ១៩.៣៩១ លានរៀល ក្នុងនោះ៖ សម្រាប់ការងាររដ្ឋបាលមានចំនួន ១១.៣៣២ លានរៀល និងអភិវឌ្ឍមានចំនួន ៨.០៥៩ លានរៀល។ គម្រោងវិនិយោគដែលបានស្នើឡើង មានចំនួន ៧២ គម្រោង និងបានធ្វើលទ្ធកម្ម(ដេញថ្លៃ)រួចចំនួន ៥៤ គម្រោង និងអនុវត្តបានតិចជាង ៥០% ចំនួន ១៥គម្រោង, ច្រើនជាង៥០% ចំនួន ១៣ គម្រោង និងបាន ១០០% ចំនួន ១៤គម្រោង។

**ចំណែកការអភិវឌ្ឍវិស័យសេដ្ឋកិច្ច សង្គមកិច្ច ក្នុងឆ្នាំ២០២០នេះ** រដ្ឋបាលខេត្តបានយកចិត្តទុកដាក់ខ្ពស់ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល សមាគម និងវិស័យឯកជននានា

ដែលត្រូវបានបង្កើតឡើងដោយស្របច្បាប់ ហើយប្រតិបត្តិការ ដោយឈរលើគោលការណ៍អភិបាលកិច្ចល្អ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សនៅមូលដ្ឋានបានល្អប្រសើរ ជាក់ស្តែងរួមមានៈ

**វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

លទ្ធផលសម្រេចបានផ្ទៃដីបានភ្ជួររាស់សរុបចំនួន ១៤៥.៣៥១ ហិកតា បានអនុវត្តដាំដុះបានចំនួន ១៤៥.៣៤២ ហិកតា ប្រៀបធៀបឆ្នាំ២០១៩ខ្ពស់ជាងឆ្នាំមុន ក្នុងនោះ៖ ស្រូវស្រាល ៧០.៧៥០ ហិកតា ស្រូវកណ្តាល ៥៣.៤៧០ ហិកតា ស្រូវធ្ងន់ ១៥.៤៧៨ ហិកតា ស្រូវចម្ការ ៨៨៣ ហិកតា ស្រូវឡើងទឹក ១.៧៦០ ហិកតា និងស្រូវបង្កើនរដូវ ៣.០០១ ហិកតា។ បន្ថែមពីនេះមានដំណាំរួមផ្សំដូចជាបន្លែគ្រប់មុខ ឪឡឹក ម្ទេស ល្ពៅ ម្នាស់ និងដំឡូងជ្វា និងដំណាំកសិឧស្សាហកម្មលក្ខណៈគ្រួសារ រួមមាន៖ ដំឡូងមី ពោតក្រហម ពោតស អំពៅ ដំណាំល្ង សណ្តែកដី សណ្តែកបាយ សណ្តែកអង្គុយ សណ្តែកសៀង ត្រាវ សាគូ ខ្ញី និងរមៀត។

**ចំពោះស្ថានភាពនៃការរងផលប៉ះពាល់ពីគ្រោះទឹកជំនន់** រួមមាន៖ **ផ្ទៃដីដំណាំស្រូវរងផលប៉ះពាល់**សរុបចំនួន ៣៧.០៩៤ ហិកតា, **ផ្ទៃដីដំណាំស្រូវខូចខាត** សរុបចំនួន ៧.៦៧៧ ហិកតា និង**ខូចខាតដំណាំចំការ**សរុបចំនួន ២.៤៩៤ហិកតា។ **ផ្ទៃដីប៉ះពាល់ដំណាំរួមផ្សំ និងដំណាំកសិឧស្សាហកម្ម** សរុប ២.៥១៤ ហិកតា និង**ដំណាំឈើហូបផ្លែ**ចំនួន ១៤៦ ហិកតា។

**ផ្ទៃដីស្តារឡើងវិញ** សរុប ៩.៤០៤ហិកតា និង **ផ្ទៃដីខូចខាត**សរុប ១៧.២៦៨ ហិកតា។ **ប៉ះពាល់ដោយទឹកជំនន់លើដំណាំរួមផ្សំ ដំណាំឧស្សាហកម្ម** និង**ដំណាំឈើហូបផ្លែ**សរុបចំនួន ១០.០៩៦ ហិកតា ស្មើនឹង ៣២,២៣% ស្មើនឹង ១៣៨ ភូមិ។

**វិស័យធនធានទឹកខេត្ត**

ប្រជាពលរដ្ឋទូទាំងខេត្ត បានទទួលមរតកជាអមតៈ គឺប្រព័ន្ធធារាសាស្ត្រទំនប់ទី៣ និងទី៥ ដែលជាអំណោយដ៏ថ្លៃថ្លារបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានឲ្យក្រសួងធនធានទឹកដឹកនាំដោយ **ឯកឧត្តម លឹម គានហោ** ស្ថាបនាទំនប់នេះឡើងដើម្បីបម្រើការស្រោចស្រពដីស្រែ ចំការ ទូទាំងខេត្ត ដែលអាចស្តុកទឹកបានជាង ៥៥ លានម៉ែត្រគូប អាចស្រោចស្រពដំណាំស្រូវបាន ១២៥.០០០ ហ.ត(មួយរយម្ភៃប្រាំពាន់ហិកតា) អាចបង្កបង្កើនផលបាន ០២-០៣ ដងក្នុងមួយឆ្នាំ។ បន្ថែមលើនេះ យើងមានប្រព័ន្ធធារាសាស្ត្រធំៗនៅផ្នែកខាងក្រោម មាន០៣កន្លែងទៀត រួមមាន៖ ប្រព័ន្ធធារាសាស្ត្រចារឹក ប្រព័ន្ធធារាសាស្ត្រដំណាក់អំពិល និងប្រព័ន្ធធារាសាស្ត្រដំណាក់ឈើក្រំ ដែលមានលទ្ធភាពស្រោចស្រពលើផ្ទៃដីសរុប ៤៥.០០០ ហិកតា និងមានប្រព័ន្ធធារាសាស្ត្រមធ្យម និងតូចសរុប ២៧កន្លែង សំណង់បង្ហៀរមានចំនួន ០៥កន្លែង ប្រឡាយមេ និងប្រឡាយរងសរុបចំនួន ១២៦ខ្សែ និងទំនប់ទី៣ ទី៥ ដែលអាចផ្ទុកទឹកសរុប ៥០ លានម៉ែត្រគូប។

**វិស័យឧស្សាហកម្ម បច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍**

មានរោងចក្រចំនួន ៥ មូលដ្ឋាន ក្នុងនោះ សហគ្រាសធុនតូច មធ្យម និងសិប្បកម្មមានចំនួន ២៤២ មូលដ្ឋាន ស្ថាននីយ៍ និងដេប៉ូចំនួន ១២០ មូលដ្ឋាន។ ជាមួយគ្នានេះដែរ ការផ្គត់ផ្គង់ទឹកស្អាតរបស់អង្គភាពរដ្ឋាករទឹកសាធារណៈមានចំនួន ០១ មូលដ្ឋាន និងការផ្គត់ផ្គង់ទឹកស្អាតរបស់អង្គភាពរដ្ឋាករទឹកឯកជនមានចំនួន ៥ មូលដ្ឋាន មានសមត្ថភាពផលិតទឹកបាន ១៣.៣០៨ ម៉ែត្រគូប/មួយថ្ងៃ។

- មានទីតាំងឧស្សាហកម្ម សហគ្រាស គ្រឹះស្ថានក្នុងខេត្តសរុបចំនួន ១៩១ កន្លែង មានកម្មករនិយោជិកសរុបចំនួន ១៣.៦០១ នាក់ ស្រី ៩.៦៩០ នាក់

- មានកម្លាំងពលកម្មសរុបប្រមាណជាង ៦០.០០០ នាក់ បច្ចុប្បន្នកម្លាំងពលកម្មប្រមាណជាង ១៣.៦០១ នាក់ទៀត ដែលកំពុងមានការងារធ្វើនៅគ្រប់គោលដៅនៃសហគ្រាសធុនតូច មធ្យម សិប្បកម្ម និងឧស្សាហកម្មកាត់ដេរ ពុំបានផ្អាកសកម្មភាពនោះទេ បើទោះបីស្ថានភាពជំងឺកូវីដ១៩ នៅតែបន្តរាតត្បាតក៏ដោយ។
- បានផ្តល់ប័ណ្ណការងារ សៀវភៅការងារជូនកម្មករនិយោជិកចំនួន ១.៤១៩ នាក់ ស្រី ១.២១៧ នាក់
- **ចុះអធិការកិច្ចការងារបានចំនួន ៥១ សហគ្រាស/គ្រឹះស្ថាន** ដើម្បីធ្វើការត្រួតពិនិត្យ បែបបទស្តីពីសហគ្រាស គ្រឹះស្ថាន និងកែលម្អលក្ខខណ្ឌការងារ អនាម័យ និងសុខសុវត្ថិភាពការងារឲ្យកាន់តែប្រសើរ។
- ដោះស្រាយវិវាទការងារសរុបចំនួន ១៨ ករណី បានដោះស្រាយចប់ចំនួន ១៧ ករណី និង០១ ករណី បន្តនីតិវិធីទៅតុលាការ។
- សម្របសម្រួលផ្តល់ព័ត៌មាន និងជួយរការងារជូនប្រជាពលរដ្ឋ បានចំនួន ១២ ករណី
- ជួយសម្របសម្រួលដល់កម្មករ កម្មការិនីជួបគ្រោះថ្នាក់ចរាចរណ៍ពេលចេញពីធ្វើការឲ្យសម្រាកព្យាបាលរបួសនៅមន្ទីរពេទ្យចំនួន ៣១ នាក់។

**វិស័យរ៉ែ និងថាមពល**

**វិស័យរ៉ែ៖** ស្ថិតិអាជីវកម្មធនធានរ៉ែដែលកំពុងដំណើរការ មានចំនួន ៣៣ទីតាំង លើអាជីវកម្មបូមខ្សាច់ អាជីវកម្មខ្សាច់បក អាជីវកម្មថ្មសំណង់ អាជីវកម្មថ្មកែវ និងអាជីវកម្មជីកអាចម៍ដី។

**វិស័យថាមពល៖** ស្ថានភាពវឌ្ឍនភាពថាមពលអគ្គិសនីទូទាំងខេត្ត មានក្រុមហ៊ុនផ្គត់ផ្គង់ និងចែកចាយអគ្គិសនីចំនួន **១៥ក្រុមហ៊ុន/សហគ្រាស**(ឯកជន)។ បណ្តាញអគ្គិសនីចូលដល់ភូមិ៤៩៨/៥១១ភូមិ ស្មើនឹង ៩៧.៤៦% ។ ប្រជាពលរដ្ឋដែលមានអគ្គិសនីប្រើប្រាស់ទូទាំងខេត្តមាន **៨៥.១០៩** ខ្នងផ្ទះ។ ថាមពលទិញពីបណ្តាញជាតិមានចំនួន ១១២,៨២៧,៣៦៤ kwh។ បន្ទុកថាមពលប្រើប្រាស់ទូទាំងខេត្តមានចំនួន ១០៤,៣៥៦,000 kwh។ ថាមពលបាត់បង់មានចំនួន ៨,៤៧១,៣៦៤ kwh។ ក្នុងនោះមានអនុស្ថានីយចំនួន៣ (១-អនុស្ថានីយអូរសោម ២-អនុស្ថានីយពោធិ៍សាត់ និងទី៣-អនុស្ថានីយស្វាយស)។ និងមានវារីអគ្គិសនី ចំនួន០២ (១-វារីអគ្គិសនីអាតៃ និងទី២-វារីអគ្គិសនីស្ទឹងពោធិ៍សាត់១។

ចំពោះអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ មានអនុភាព ៩០មេហ្គាវ៉ាត់ បច្ចុប្បន្នបានដំណើរការផលិតថាមពលបានចំនួន ៦០មេហ្គាវ៉ាត់ហើយ ចំណែកនៅសល់ចំនួន៣០មេហ្គាវ៉ាត់ទៀត ក្រុមហ៊ុននឹងដំណើរការឱ្យបានចប់នៅត្រីមាសទី១ នៃឆ្នាំ២០២១នេះ ហើយមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ បានផ្តល់ផ្ទាំងសូឡាចំនួន ២.៥០០ប្រព័ន្ធ ចែកចេញជា ៣កម្លាំង៖ ១-កម្លាំង ១០ (W) ចំនួន ១.២០០ប្រព័ន្ធ២-កម្លាំង ៨០ (W) ចំនួន ១.០០០ប្រព័ន្ធ និងទី៣-កម្លាំង ៣០០ (W) ចំនួន ៣០០ប្រព័ន្ធ។

**វិស័យអភិវឌ្ឍជនបទខេត្ត**

សម្រេចបានលទ្ធផលរួមមាន ផ្លូវក្រាលកៅស៊ូស្តារឡើងវិញ (១ខ្សែប្រវែង ៣,៨ គីឡូ ម៉ែត្រ) ផ្លូវបេតុងស្តារឡើងវិញ (ប្រវែង៦០០ម៉ែត្រ) ផ្លូវក្រាលគ្រួសក្រហម(៤គម្រោង ប្រវែង ១៥.២៥១ ម៉ែត្រ) លើកផ្លូវដីស(២០០ គម្រោង ប្រវែង ១៨៤.២៩៧ ម៉ែត្រ) ផ្លូវថែទាំប្រចាំ(១៤ខ្សែប្រវែង ៩៧,៧០គីឡូម៉ែត្រ) ផ្លូវថែទាំខួប(៣ខ្សែប្រវែង ១៦,១០ គីឡូម៉ែត្រ) សាងសង់លូប្រអប់(២កន្លែង) ផ្លូវជួសជុលបន្ទាន់(៧ខ្សែប្រវែង ៥១,៥១០ម៉ែត្រ) សាងសង់

អណ្តូងស្នប់(១៩១អណ្តូង) ផ្តល់បង្គន់អនាម័យ(១៤២បង្គន់) ផ្តល់ពាងចំណុះ ១.០០០ លីត្រ(៧២៩ពាង) និងបានសាងសង់ស្រះសហគមន៍ ៥០x៥០ (៦កន្លែង)។

**វិស័យទេសចរណ៍**

មានកន្លែងទេសចរណ៍ធម្មជាតិ សាសនា និងវប្បធម៌ចំនួន ៣៥ កន្លែង ក្នុងនោះមាន ១០ កន្លែងបាន និងកំពុងអភិវឌ្ឍន៍ដោយសហគមន៍មូលដ្ឋាន និងកំពុងស្វែងរកដៃគូឯកជនដើម្បីវិនិយោគ។ ក្នុងឆ្នាំ២០២០ មានស្ថិតិភ្ញៀវទេសចរសរុបចំនួន **៤៤០.៩២៩នាក់** ក្នុងនោះ ភ្ញៀវទេសចរជាតិមានចំនួន **៤៣៨.៥៥៣នាក់** និងភ្ញៀវទេសចរអន្តរជាតិមានចំនួន **២.៣៧៦នាក់**។ តំបន់ទេសចរណ៍ ដែលមានសក្តានុពលក្នុងខេត្តរួមមាន៖ បុរីវប្បធម៌កោះសំពៅមាស មូជនីយ៍ដ្ឋានប្រវត្តិសាស្ត្រឧកញ៉ាឃ្លាំងមឿង តំបន់ទេសចរណ៍បឹងទន្លេសាប,ទឹកធ្លាក់ច្រកល្បៀង, ល្បាក់កំពាញ, ទេសចរណ៍ធម្មជាតិភ្នំ១៥០០ ឬហៅថាផ្លូវបុប្ផាលាក់ខ្លួន, ទឹកធ្លាក់ថ្មដាតូច ថ្មដាធំ និងតំបន់ទេសចរណ៍ធម្មជាតិ និងច្នៃប្រឌិតជាច្រើនកន្លែងទៀត សម្រាប់ទាក់ទាញភ្ញៀវទេសចរណ៍ជាតិ អន្តរជាតិ។

សក្តានុពលដែលជាការចាប់អារម្មណ៍ខ្លាំង និងទស្សនៈវិស័យអភិវឌ្ឍន៍របស់ថ្នាក់ដឹកនាំខេត្តចម្បង គឺការលើកកម្ពស់ទេសចរណ៍ធម្មជាតិនៅឃុំអូរសោម ស្រុកវាលវែង ដែលជាតំបន់ដ៏មានសក្តានុពលខ្លាំង ក្នុងការលើកកម្ពស់សេដ្ឋកិច្ចប្រជាពលរដ្ឋក្នុងតំបន់ ក៏ដូចជាខេត្តពោធិ៍សាត់តាំងមូលផងដែរ។ ឃុំអូរសោម មានលក្ខណៈអំណោយផលខ្លាំង មានអាកាសធាតុត្រជាក់ត្រូវពិច បើប្រៀបធៀបនឹងនីវូទឹកសមុទ្រមានរយៈកំពស់ ៦៥០ ម៉ែត្រ ដែលធ្វើឲ្យតំបន់នេះ សម្បូរទៅដោយធនធានធម្មជាតិ តំបន់ទេសចរណ៍ធម្មជាតិ រួមមាន៖

- ទេសចរណ៍ធម្មជាតិនៅតំបន់ទឹកធ្លាក់ ទេសចរណ៍សត្វក្រពើភ្នំ ទេសចរណ៍ស្ទូចត្រី និងបេះផ្លែឈើធម្មជាតិ
- កសិដ្ឋានដំណាំបន្លែ ចំនួន ០៣ កសិដ្ឋាន អាចផលិតបាន ៣-៤ តោន/ថ្ងៃ
- ទីតាំងរមនីយដ្ឋានធម្មជាតិជាច្រើនកន្លែង ដែលអាចទាក់ទាញអ្នកវិនិយោគជាតិ អន្តរជាតិ មកវិនិយោគក្នុងវិស័យទេសចរណ៍ធម្មជាតិ
- ទំនប់វារីអគ្គិសនីដ៏ធំមួយក្នុងខេត្ត។

ទស្សនៈវិស័យរបស់ថ្នាក់ដឹកនាំខេត្ត គឺមានគម្រោងច្នៃតំបន់នេះ ទៅជាតំបន់ទេសចរណ៍ធម្មជាតិ និងការនាំចេញនៅហ្នឹងកន្លែង ដើម្បីលើកកម្ពស់សេដ្ឋកិច្ចប្រជាពលរដ្ឋ។

**ទីចាត់ការផែនការវិនិយោគ**

មានក្រុមហ៊ុនវិនិយោគឯកជនសរុបចំនួន **១៨ ក្រុមហ៊ុន** បាន និងកំពុងសហការបង្កើតរោងចក្រ ដែលបានបោះទុនវិនិយោគសរុបប្រមាណជាង **១.០០០ លានដុល្លា** មានដូចខាងក្រោម៖

1. រោងចក្រកាត់ដេរតៃអ៊ីហ្សី នៅឃុំអន្លង់ត្នោត ស្រុកក្រគរ
2. ក្រុមហ៊ុនរតនាវិសាល វិនិយោគលើវិស័យកសិកម្ម នៅស្រុកក្រគរ
3. ក្រុមហ៊ុនភាពីម៉ិច វិនិយោគវិស័យកសិកម្ម នៅស្រុកក្រគរ
4. ក្រុមហ៊ុន ស៊ិនលីយីផៅវ៉ វិនិយោគតំឡើងត្រង់ស្វូ នៅស្រុកក្រគរ
5. ក្រុមហ៊ុនឌីឌីអឹមអិល វិនិយោគការកិនថ្ម ស្រុកក្រគរ
6. ក្រុមហ៊ុន ស្នេថេក អ៊ីនហ្វីនីត ឯក. (Schneitec infinite co.,LTD) វិនិយោគលើថាមពលអគ្គិសនីដោយពន្លឺព្រះអាទិត្យ នៅស្រុកក្រគរ

7. ក្រុមហ៊ុនផលិតគ្រឿងសំណង់អេឡិចត្រូនិចដែលមានប្រសិទ្ធិភាព(ខេមបូឌា)លីមីតធីត (Precise electric manutacturing) ផលិតត្រង់ស្វូរ និងផ្គុំតំឡើង Swichboard នៅស្រុកក្រគរ
8. ក្រុមហ៊ុនថូភេក អេឡិចទ្រីក ឯ.ក (Topec Electric Co.,LTD) ផលិតខ្សែភ្លើងគ្រប់ប្រភេទ នៅស្រុកក្រគរ
9. ក្រុមហ៊ុន វ៉ាន់នីបាយអូរីសើច វិនិយោគចិញ្ចឹមស្វា នៅក្រុងពោធិ៍សាត់
10. ក្រុមហ៊ុនលានហ្វាដាស៊ុង វិនិយោគដាំដំណាំកប្បាស នៅស្រុកបាកាន
11. ក្រុមហ៊ុនលានហ្វាហេងយូ វិនិយោគកាត់ដេរសំលៀកបំពាក់ នៅស្រុកបាកាន
12. ក្រុមហ៊ុន អឹមឌីអេស១ វិនិយោគដាំដំណាំកសិកម្ម នៅស្រុកវាលវែង
13. ក្រុមហ៊ុន អឹមឌីអេស២ វិនិយោគតំបន់សេដ្ឋកិច្ចពិសេសហុងហ៊ី នៅស្រុកវាលវែង
14. ក្រុមហ៊ុនអគ្គិសនីអាតៃ វិនិយោគផលិតថាមពលអគ្គិសនី នៅស្រុកវាលវែង
15. ក្រុមហ៊ុន SPHP (អគ្គិសនីស្ទឹងពោធិ៍សាត់១) ផលិតអគ្គិសនី នៅស្រុកវាលវែង
16. ក្រុមហ៊ុនញូវថូស៊ីហូមវ៉ា (Newtoshi homewear Co.,LTD) រោងចក្រកាត់ដេរសំលៀកបំពាក់ និងស្រោមដៃ នៅស្រុកក្រគរ
17. ក្រុមហ៊ុនអេមអេឡិចទ្រីក (Emax Electrice) វិនិយោគតម្លើងត្រង់ស្វូរ និងសម្ភារៈបរិក្ខាអគ្គិសនី នៅស្រុកក្រគរ
18. ក្រុមហ៊ុនស្នេថេក សាស្ទែនេប៊ល (Schneitec Sustainable co.,LTD) ផលិតថាមពលអគ្គិសនីដោយពន្លឺព្រះអាទិត្យ នៅស្រុកក្រគរ

**វិស័យពាណិជ្ជកម្ម**

ស្ថិតិក្រុមហ៊ុន សហគ្រាសពាណិជ្ជកម្ម និងអាជីវកម្មមានចំនួនសរុប **៥.៥៦៣ មូលដ្ឋាន** ក្នុងនោះមន្ទីរក៏បានចុះជំរុញមូលដ្ឋានកសិករ ពាណិជ្ជករ ឱ្យចូលរួមអនុវត្តការងារភូមិមួយផលិតផលមួយដែលបានចងក្រងសមាគមន៍អាជីវកម្មចំនួន២ គឺ**សមាគមន៍អាជីវកម្មក្រូចពោធិ៍សាត់អង្រ្គង** មានសមាជិកចំនួន ១១៥ គ្រួសារ និង **សមាគមន៍ដំឡូងមី** មានសមាជិកចំនួន ២៨១ គ្រួសារ។ ម្យ៉ាងទៀត មានរោងម៉ាស៊ីនកិនស្រូវសម្រាប់នាំចេញក្រៅស្រុក និងក្នុងស្រុកចំនួន**១០កន្លែង** ឡសម្ងួតសរុប **៦៣ឡ** ដែលមានលទ្ធភាពនាំចេញបានចំនួន **១១.២៥៤ តោន** ក្នុងឆ្នាំ២០២០។

មន្ទីរបាន និងកំពុងរៀបចំជំរុញផលិតផលសក្តានុពលក្នុងខេត្ត ជាច្រើនរួមមានស្រូវ អង្ករ ត្រី ដំឡូងមី កៅស៊ូ ម្រេច ពោតក្រហម ធូរ៉េន មៀនប៉ៃលិន ស្វាយកែវល្មៀត ស្ករត្នោត ចម្លាក់ថ្មកែវ ជាពិសេសក្រូចពោធិ៍សាត់ ដែលកំពុងរៀបចំកិច្ចដំណើរការនៃការកសាងនិតីវិធីចុះជាម៉ាកសមូហភាព«ក្រូចពោធិ៍សាត់» សម្រាប់អ្នកដាំដុះក្រូចពោធិ៍សាត់ និងអាជីវករក្នុងខេត្តពោធិ៍សាត់ទាំងអស់បានប្រើប្រាស់ម៉ាកសមូហភាពនេះរួមគ្នា ដើម្បីទាក់ទាញអ្នកវិនិយោគទាំងក្នុងខេត្ត ក្រៅខេត្ត និងឈានដល់ក្រៅប្រទេសឱ្យកាន់តែច្រើនពីមួយឆ្នាំទៅមួយឆ្នាំ។

**វិស័យសុខាភិបាល**

មន្ទីរសុខាភិបាលខេត្ត មានការិយាល័យស្រុកប្រតិបត្តិចំនួន ០៤ មន្ទីរពេទ្យបង្អែកចំនួន ០៤ មណ្ឌលសុខភាពចំនួន ៤០ និងប៉ុស្តិ៍សុខភាពចំនួន០២ ដោយមានគម្រោងមូលនិធិសមធម៌(មសស) និងបេឡាជាតិរបបសន្តិសុខសង្គម(បសស) គ្រប់ដណ្តប់គ្រប់មន្ទីរពេទ្យ និងមណ្ឌលសុខភាពទាំងអស់ក្នុងខេត្ត។

**អំពីស្ថានភាពជំងឺកូវីដ១៩នៅក្នុងខេត្តពោធិ៍សាត់ គឺតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ស្ថិតិប្រជាពលរដ្ឋមកពីក្រៅប្រទេស**សរុបចំនួន ៣.៤៥៤ នាក់ ស្រី១.៥៨៧នាក់ បានធ្វើការអប់រំណែនាំដោយផ្ទាល់ទាំងអស់។ ចំនួនអ្នកបានធ្វើចត្តាឡីស័កសរុប ១.៤៦៦ នាក់ ក្នុងនោះបានបញ្ចប់ការធ្វើចត្តាឡីស័កសរុប ១.៣៧៤ នាក់។

**អំពីស្ថិតិ និងស្ថានភាពរីករាលដាលនៃជំងឺកូវីដ១៩៖** ចំនួនជនសង្ស័យបានធ្វើតេស្តសំណាកសរុបចំនួន ៨៥៧នាក់ ស្រី៣៥២នាក់ ក្នុងនោះ ចំនួនលទ្ធផលអវិជ្ជមានទាំងអស់។

**ចំពោះវិធានការផ្សព្វផ្សាយប្រចាំថ្ងៃ៖** បានប្រើប្រាស់នូវវិធានការ (ប្រយោល) ដោយធ្វើការផ្សព្វផ្សាយតាមរយៈវិទ្យុ ឧគ្ឃោសនាសព្ទ បណ្តាញសង្គម បណ្តាញយុវជន បណ្តាញសហគមន៍ និងផ្ទាំងផ្សាយ LED ។

## វិស័យដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី

ការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធក្នុងឆ្នាំ២០២០ សម្រេចបានរួមមាន ៖ប្រកាសតំបន់វិនិច្ឆ័យបានចំនួន ១៤ភូមិ, វិនិច្ឆ័យសរុបបានចំនួន ១៩.៩០៧ ក្បាលដី, វាស់វែងសរុបបានចំនួន ២២.៤៧៨ ក្បាលដី, បញ្ចូលទិន្នន័យសរុបបានចំនួន ១៩.៩៥៦ ក្បាលដី, គូរក្បាលដីសរុបបានចំនួន ១៨.០៦០ ក្បាលដី, បានបិទផ្សាយជាសាធារណៈចំនួន ៧.៩៨៤ ក្បាលដី បានចុះហត្ថលេខាលើវិញ្ញាបនបត្រចំនួន ១៥.៤៣៣ ប័ណ្ណ និងបានប្រគល់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុចំនួន ១១.៩៦៥ ប័ណ្ណ។

**ការងារច្រកចេញចូលតែមួយ មន្ទីរសម្រេចលទ្ធផលបាន៖** ចុះបញ្ជីដំបូង(ជាប្រព័ន្ធ) ចំនួន ២.០៤៣ ក្បាលដី, ចុះបញ្ជីដំបូង (បំពេញបន្ថែម)ចំនួន ៩២ក្បាលដី, ចុះបញ្ជីបន្ត(លក់ផ្តាច់,បំបែកក្បាលដី,អំណោយ) ចំនួន១.៧៩៥ ក្បាលដី,។ បង្រួមក្បាលដីចំនួន ១៩ ក្បាលដី, កែប្រែប្រភេទដីចំនួន ០៨ ក្បាលដី, ទុតិយតាចំនួន ២៤ ក្បាលដី, ស្វែងរកចំណុចព្រំចំនួន ២៦ ក្បាលដី, និងកែតម្រូវសារវតាចំនួន ២១១ ក្បាលដី។

**ការងាររៀបចំដែនដី និងនគរូបនីយកម្ម៖** ការងារកសាងប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ថ្នាក់ក្រុង និងទីប្រជុំជន គឺបានកំពុងបន្តរៀបចំផែនទីភូមិ សម្រាប់គម្រោងការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធក្នុងភូមិ-ឃុំ គោលដៅ និងកំពុងរៀបចំប្លង់ប្រើប្រាស់ដីធ្លីក្រុងស្រុក សម្រាប់ឆ្នាំ២០៣៥ ។

**ការងារសំណង់៖** សំណង់មានការអនុញ្ញាតមានចំនួន ២៤គម្រោង មានផ្ទៃក្រឡាសំណង់ ៣,៣៩០.៦៥ ម$^{២}$ មានទុនវិនិយោគចំនួន ៧៤៧.១៩៥ ដុល្លារ ។

## វិស័យសាធារណការ និងដឹកជញ្ជូនខេត្ត

ជាកត្តិយសដ៏ខ្ពង់ខ្ពស់បំផុត ខេត្តពោធិ៍សាត់ បានទទួលវត្តមានដ៏ឧត្តុងឧត្តមរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីសម្ពោធផ្លូវជាតិលេខ៥៥ មានប្រវែងសរុប ១៨៦ គីឡូម៉ែត្រ តភ្ជាប់ពីផ្លូវជាតិលេខ៥ ទៅឃុំថ្មដា ស្រុកវាលវែង ដែលសម្តេចបានប្រសិទ្ធនាមថា "**ផ្លូវបុប្ផាលាក់ខ្លួន**" និងបើកការដ្ឋានសាងសង់ផ្លូវជាតិលេខ១០ តភ្ជាប់ពីស្រុកវាលវែង ទៅស្រុកសំឡូតខេត្តបាត់ដំបង និងទៅខេត្តកោះកុង។

បណ្តាញផ្លូវដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តពោធិ៍សាត់មានចំនួន ៣៨ខ្សែ ប្រវែងសរុប ៨៩៣,១៦ គ.ម រួមមាន៖ ផ្លូវជាតិ១លេខ ចំនួន១ខ្សែ ប្រវែង ៨៦,៣០ គ.ម ផ្លូវជាតិ២លេខចំនួន ៥ខ្សែ ប្រវែង ៣៣០,៧៨ គ.ម ផ្លូវខេត្តចំនួន ៣២ខ្សែ ប្រវែង ៤៧៦,០៨ គ.ម និងស្ពានសរុបចំនួន ១៩០ ប្រវែង ៤៧៤៦ម៉ែត្រ លូគ្រប់ប្រភេទប្រវែង ៩.២៧៨ម៉ែត្រ។ ផ្លូវក្នុងក្រុងពោធិ៍សាត់មានចំនួន ៧៦ខ្សែ ប្រវែង ៥៧,៥៤ គ.ម (ក្រាលកៅស៊ូប្រវែង ៣៥,៣៧ គ.ម) និងលូគ្រប់ប្រភេទចំនួន ២.៣៩៥ម៉ែត្រ។

## III. ទិសដៅការងារសម្រាប់ឆ្នាំ២០២១ របស់រដ្ឋបាលខេត្ត

ដើម្បីធានាដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច និងវិស័យផ្សេងៗទៀតឱ្យមានការអភិវឌ្ឍរីកចម្រើនតាមកំណែទម្រង់រដ្ឋបាលសាធារណៈនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងគោលនយោបាយនានា របស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា និងក្រសួងមហាផ្ទៃ ធ្វើឱ្យប្រសើរឡើង និងឆ្លើយតបទាន់ពេលវេលាទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនោះ រដ្ឋបាលខេត្តសូមដាក់ចេញនូវទិសដៅសកម្មភាពសម្រាប់ឆ្នាំ២០២១ មានដូចខាងក្រោម៖

- ចូលរួមពិនិត្យ និងដោះស្រាយសំណើ សំណូមពរ បញ្ហាប្រឈម និងកង្វល់នានាដែលប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋានបានស្នើឡើងស្របតាមច្បាប់ គោលការណ៍ និងលិខិតបទដ្ឋានគតិយុត្ត។
- ជំរុញការតាមដាន វាយតម្លៃការអនុវត្តសេចក្តីសម្រេច របស់ក្រុមប្រឹក្សាដែលបានដាក់ចេញក្នុងពេលកន្លងមក ពិសេសការអនុវត្តផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ដែលបានសម្រេចដាក់ចេញសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមក្នុងខេត្ត ឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យ គោលដៅ និងគោលបំណងនៃការអភិវឌ្ឍក្នុងអាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្ត។
- បន្តប្រាស្រ័យទំនាក់ទំនងជាមួយយន្តការរបស់ក្រុមប្រឹក្សា និងប្រជាពលរដ្ឋ ដើម្បីមានមូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងខាងប្រតិបត្តិ បានកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនៅជាធរមាន។
- អនុវត្តកម្មវិធីប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា ដែលបានកំណត់ក្នុងប្រតិទិនប្រជុំ និងស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា ព្រមទាំងច្បាប់ លិខិតបទដ្ឋានគតិយុត្ត។
- បន្តរៀបចំផែនការសម្រាប់ធ្វើវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សានៅតាមមូលដ្ឋានក្រុង ស្រុកទាំង៧ ក្នុងអំឡុងត្រីមាសទី៤ នៃឆ្នាំនីមួយៗ។
- បង្កើនការអប់រំផ្សព្វផ្សាយពីការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយនានា ដើម្បីរៀបចំព្រមទាំង អនុវត្តផែនការគ្រប់គ្រងគ្រោះមហន្តរាយ ដែលឈានទៅកាត់បន្ថយ នូវផលប៉ះពាល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋយ៉ាងមានប្រសិទ្ធភាព។
- ពង្រឹងការគ្រប់គ្រងរដ្ឋបាល និងបង្កើននូវការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ធានាបាននូវកិច្ចការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈជូនប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង។
- ការពង្រឹង និងបង្កើនការយកចិត្តទុកដាក់លើការផ្តល់សេវាសាធារណៈ ជូនប្រជាពលរដ្ឋទូទៅឱ្យកាន់តែមានភាពប្រសើរឡើង។
- បង្កើន និងលើកកម្ពស់ការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស ដែលធានានូវការលើកកម្ពស់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព។
- បន្តលើកកម្ពស់ យន្តការគណនេយ្យភាពតាមរយៈប្រអប់សំបុត្រគណនេយ្យភាព និងការរៀបចំវេទិកាផ្សព្វផ្សាយពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ដើម្បីក្តាប់បាននូវសំណូមពរ និងបញ្ហានានានៅមូលដ្ឋាន និងដាក់ចេញនូវវិធានការឆ្លើយតបប្រកបដោយប្រសិទ្ធភាព។
- រដ្ឋបាលខេត្ត បាន និងកំពុងស្វែងដៃគូវិនិយោគឯកជនមកធ្វើការវិនិយោគវិស័យនានាក្នុងខេត្ត។

ជាចុងក្រោយក្នុងនាមក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក គណៈអភិបាលក្រុង ស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ មន្ត្រីរាជការ កងកម្លាំង និងប្រជាពលរដ្ឋ គ្រប់លំដាប់ថ្នាក់ទូទាំងខេត្តពោធិ៍សាត់

សូមថ្លែងគោរពអំណរគុណចំពោះសម្តេច និងសូមសម្តេចបន្តការដឹកនាំប្រទេសជាតិតទៅទៀតដើម្បីឱ្យមានការរីកចំរើនជាបន្តបន្ទាប់ក្រោមម្លប់សន្តិភាព ដែលសម្តេចបានយកជីវិតទៅប្តូរ ដើម្បីនាំយកសន្តិភាពមកជូនជាតិមាតុភូមិ ធ្វើឱ្យមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ប្រជាពលរដ្ឋក្នុងខេត្ត ចងចាំមិនអាចភ្លេចបាន។ សូមគោរពជូនពរ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** បុត្រាបុត្រី និងចៅៗរបស់សម្តេច សូមប្រកបដោយបញ្ញាឈ្លាសវៃ សុខភាពល្អ ដើម្បីដឹកនាំប្រទេសជាតិប្រកបដោយសន្តិភាព និងអភិវឌ្ឍន៍រីកចំរើនលើគ្រប់វិស័យបន្តទៀត។

ជាទីបញ្ចប់នេះ ខ្ញុំបាទសូមគោរពជូនពរ **ឯកឧត្តម ផៃ ស៊ីផាន រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី** សូមទទួលបានជោគជ័យគ្រប់ភារកិច្ច និងសូមគោរពជូនពរលោកជំទាវ ឯកឧត្តម លោក លោកស្រី ទាំងអស់ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ៖ **អាយុ វណ្ណៈ សុខៈ និងពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ៕